# ការសិក្សាបង្ហាញថាអ្នកចូលចិត្តទទួលទានសាច់ឆៅប្រឈមមុខនឹងការឆ្លងព្រូនម៉្យាងដែលបង្កជំងឺមហារីក និងក្រិនថ្លើម

**ភ្នំពេញៈ** ការសិក្សាបឋមមួយនៅកម្ពុជាបានបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាដែលទទួលទានសាច់ឆៅ ប្រឈមមុខនឹងការឆ្លងដង្កូវថ្លើម ដែលបង្កជាជំងឺមហារីកក្រិនថ្លើមនិងជំងឺរលាកទឹកប្រមាត់។

លោកវេជ្ជបណ្ឌិត ច ម៉េងជួរ ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រក្រសួងសុខាភិបាលបានមានប្រសាសន៍ឱ្យដឹងកាលពីថ្ងៃទី១១មករាកន្លងមកថា ប្រជាជនកម្ពុជាដែលចូលចិត្តទទួលទានសាច់ជ្រូក សាច់គោ និងត្រីឆៅប្រឈមមុខនឹងការឆ្លងដង្កូវថ្លើម ដែលបង្កឱ្យមានផលវិបាកធ្ងន់ធ្ងរដល់សុខភាពដូចពោលខាងលើ ។ លោកបន្តថាពពួកដង្កូវថ្លើមទាំងនោះបានបង្កប់ពងរបស់វាក្នុងពពួកសាច់ទាំងនោះ ហើយវាចេញមកវិញតាមរយៈការបន្ទោបង់ ពាសវាលពាសកាលហូរចូលទៅក្នុងបឹង ស្ទឹងទន្លេ ដែលធ្វើឱ្យត្រី ឬ ពពួកសត្វនានាឆ្លងពងដង្កូវទាំងនោះ ហើយយើងនឹងឆ្លងពងដង្កូវព្រូនទាំងនោះតាមរយៈការទទួលទានសាច់ឆៅប៉ុន្តែបើយើងចម្អិនឱ្យឆ្អិនពងដង្កូវព្រូនទាំងនោះនឹងងាប់។លោកបន្តថាតាមការសិក្សាមួយទៅលើប្រជាជនរស់នៅឃុំអង្គស្វាយចេក ខេត្តតាកែវបានរកឃើញថាប្រជាពលរដ្ឋក្នុងឃុំនោះ៥៤ភាគរយមានផ្ទុកពងដង្កូវថ្លើមក្នុងខ្លួន ហើយការសិក្សានៅឃុំស្វាគង ក្នុងខេត្តកំពង់ចាមបានរកឃើញថា ប្រជាពលរដ្ឋក្នុងឃុំនោះមានផ្ទុកពងដង្កូវថ្លើម២៣ភាគរយ និង៩ភាគរយនៅឃុំរាយប៉ាយ ខេត្តកំពង់ចាម ។ ការសិក្សាដែលនេះទៅលើកុមារនៅសាលារៀនមួយក្នុងខេត្តតាកែវបានរកឃើញកុមារចំនួន១១ភាគរយមានផ្ទុកពងដង្កូវថ្លើម។

លោកវេជ្ជបណ្ឌិត ច ម៉េងជួរ បានមានប្រសាសន៍ថា "ព្រូនប្រភេទផ្សេងៗទៀតយើងអាចគ្រប់គ្រងបានហើយ ប៉ុន្តែពពួកដង្កូវព្រូនថ្លើមនេះយើងកំពុងសិក្សា ដើម្បីរកវិធីសាស្ត្រព្យាបាល និងគ្រប់គ្រងវា" ។

យោងតាមការសិក្សារបស់ក្រសួងសុខាភិបាលបានបង្ហាញថា កម្ពុជាមានពពួកព្រូនបីប្រភេទ ទីមួយពពួកព្រូនដែលឆ្លងមកមនុស្សតាមរយៈដីតាមរយៈការទទួលទានបន្លែនានា ហើយព្រូនប្រភេទនេះ មានកម្មវិធីបញ្ចុះពីរលើកក្នុងមួយឆ្នាំ ដែលមានអត្រាគេបង្កើនការផ្តល់ថ្នាំទម្លាក់ព្រូនពី៩០ទៅ៩៥ភាគរយ តាមរយៈការផ្តល់ថ្នាំទម្លាក់ព្រូនដល់កុមារនៅតាមសាលាបឋមសិក្សា និងតាមរយៈយុទ្ធនាការផ្តល់ថ្នាំបង្ការ ទីពីរប្រភេទព្រូនដែលមានជាប់ជាមួយពពួកខ្យង ដែលមាននៅតាមដងទន្លេនាខេត្តក្រចេះ និងស្ទឹងត្រែង។ ព្រូនប្រភេទនេះបណ្តាលឱ្យអ្នកជំងឺធំពោះ និងកើតជំងឺមហារីក។ រហូតមកទល់ពេលនេះអត្រាឆ្លងពពួកព្រូននេះ មកប្រជាជនក្នុងតំបន់បានធ្លាក់ចុះមកត្រឹមប្រមាណ៥ភាគរយ និងប្រភេទព្រូនទីបីគឺពពួកព្រូនដង្កូវថ្លើម ដែលឆ្លងតាមរយៈការទទួលទានសាច់ត្រី សាច់គោ សាច់ជ្រូកឆៅ ហើយពពួកព្រូនទាំងនេះបណ្តាលឱ្យប្រជាពលរដ្ឋកើតជំងឺមហារីកថ្លើម ក្រិនថ្លើម និងរលាកទឹកប្រមាត់៕ **ប្រាយ ចំណាន**